**Embassy of Japan in Cambodia**

# Press Release / Media Invitation

No. 06 PR-26/EoJ

30 January 2026

## Japan-Cambodia Kizuna Festival 2026

The Embassy of Japan, in collaboration with the Cambodia-Japan Cooperation Center (CJCC) and the Japan Foundation, Phnom Penh Liaison Office, is going to organize the 15th Japan-Cambodia Kizuna Festival, one of the biggest Japan-Cambodia cultural events, from 5 to 8 February 2026 at CJCC. **The opening ceremony of this festival will be held on Thursday, 5 February, from 18:00 to 19:30.** In this regard, as one of the co-organizers, the Embassy of Japan would like to invite all interested media to cover the opening ceremony and other events.

The tentative agenda of opening ceremony is enclosed. Other events are introduced in the pamphlet and you can see the detailed programs from this website: https://www.kh.emb-japan.go.jp/itpr_en/11_000001_01307.html. We would like to highlight that the theme of this year's festival is "***Exploring a New Gateway – The Beginning of a New Journey Connecting Japan and Cambodia***". By engaging in diverse cultural activities through participatory experiences of both traditional and contemporary, we explore and enhance the two countries' bond as shown in the name of this festival.

This year's sponsors are SATHAPANA Bank Plc., DAIICHI LIFE INSURANCE (CAMBODIA) PLC., Air Cambodia Co., Ltd., BUDDY'S MARKETING JP CO., LTD., MEGUMI VOCATIONAL EDUCATION SCHOOL, GUNZE SPORTS (Cambodia) CO., LTD., J Trust Royal Bank Plc., Active People's Microfinance Institution Plc, Panasonic Cambodia (Branch of Panasonic Asia Pacific Pte. Ltd.).

Japan-Cambodia Kizuna Festival is an annual event which has been organized since 2012 for the purpose of presenting the culture of Japan and Cambodia and promoting further exchanges between the people of both countries. We hope that through these cultural events, the participants feel closer to Japan and deepen their understanding of Japanese and Cambodian culture.

For media registration and inquiries, please contact Culture and Information Section at 023 217 161 (Ext: 1121) or email: info.jpn@pp.mofa.go.jp. For more information of the festival, please visit the Facebook account "Japan Cambodia Kizuna & Tanabata".

ស្ថានទូតជប៉ុនប្រចាំនៅកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន
# និង លិខិតអញ្ជើញអ្នកសារព័ត៌មាន

No. 06 PR-26/EoJ

ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៦

## មហោស្រពគីហ្សូណាជប៉ុន-កម្ពុជា២០២៦

ស្ថានទូតជប៉ុន រួមសហការជាមួយមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន(CJCC) ការិយាល័យទំនាក់ទំនងភ្នំពេញនៃមូលនិធិជប៉ុន នឹងរៀបចំនូវមហោស្រពគីហ្សូណាជប៉ុន-កម្ពុជាលើកទី១៥ ដែលជាកម្មវិធីវប្បធម៌ដ៏ធំមួយ នឹងប្រព្រឹត្តិទៅចាប់ពីថ្ងៃទី៥ ដល់ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៦ នៅCJCC។ **ពិធីបើកមហោស្រពនេះនឹងប្រព្រឹត្តិទៅនៅថ្ងៃព្រហស្បតិ៍ ទី៥ ខែកុម្ភៈ ចាប់ពីម៉ោង១៨:០០ ដល់ម៉ោង១៩:៣០។** អាស្រ័យហេតុនេះ ក្នុងនាមជាស្ថាប័នសហការរៀបចំ ស្ថានទូតជប៉ុន សូមគោរពអញ្ជើញអ្នកសារព័ត៌មាន ចូលរួមយកព័ត៌មានក្នុងពិធីបើក ព្រមទាំងកម្មវិធីផ្សេងៗនៃមហោស្រពនេះកុំបីខាន។

កាលវិភាគកម្មវិធីពិធីបើកមហោស្រពមានជូនភ្ជាប់។ សម្រាប់កម្មវិធីនានាដែលនឹងប្រព្រឹត្តទៅអំឡុងពេលមហោស្រពនេះ សូមមើលលើខិត្តប័ណ្ណដែលរៀបរាប់កម្មវិធីលម្អិត តាមរយៈតំណរភ្ជាប់នេះ៖ https://www.kh.emb-japan.go.jp/itpr_en/11_000001_01307.html។ យើងខ្ញុំសូមជម្រាបជូនថា ប្រធានបទ នៃមហោស្រពឆ្នាំនេះគឺ «**គន្លងថ្មីសម្រាប់ភ្ជាប់ជប៉ុន និងកម្ពុជា**»។ តាមរយៈការចូលរួមសកម្មភាពវប្បធម៌ចម្រុះនានា និងបទពិសោធន៍ផ្ទាល់ ទាំងបែបប្រពៃណី និងសហសម័យ យើងនឹងរួមគ្នាស្វែងយល់ ព្រមទាំងពង្រឹងចំណងមិត្តភាពរវាងប្រទេសទាំងពីរដូចទៅនឹងឈ្មោះមហោស្រពនេះ។

ក្រុមហ៊ុមចូលរួមឧបត្ថម្ភក្នុងមហោស្រពឆ្នាំនេះមានដូចជា ធនាគារ ស្ថាបនា, ក្រុមហ៊ុន ដាយ អ៊ិឈិឡាយហ្វ៍, ក្រុមហ៊ុនអាកាសចរណ៍ជាតិកម្ពុជា, ក្រុមហ៊ុនបាឌី ម៉ាឃីធីង ជេភី ឯ.ក, សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ មេហ្គូមី, ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់ ម.ក, ហ្គាន់ហ្សេ ស្ព័ត (ខេមបូឌា) ខូ អិលអីឌី, គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អាក់ទីវភីភល ភីអិលស៊ី, សាខាក្រុមហ៊ុនប៉ាណាសូនិក អេស៊ា ផេស៊ីហ្វិក ភីធីអ៊ី អិលធីឌី។

*Embassy of Japan in the Kingdom of Cambodia*
*Tel: 023 217 161*
*Email: info.jpn@pp.mofa.go.jp*
*Official Website: www.kh.emb-japan.go.jp*

ជាក់ស្តែង មហោស្រពគីហ្សូណាជប៉ុន-កម្ពុជា ត្រូវបានរៀបចំឡើងជារៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ ២០១២ ក្នុងគោលបំណងបង្ហាញពីវប្បធម៌ជប៉ុន និងកម្ពុជា ក៏ដូចជាការជម្រុញការផ្លាស់ប្តូរនានារវាងប្រជាជននៃប្រទេសទាំងពីរផងដែរ។ យើងខ្ញុំសង្ឃឹមថា អ្នកចូលរួម នឹងមានអារម្មណ៍កាន់តែស្និទ្ធស្នាលជាមួយប្រទេសជប៉ុន និងបានយល់ដឹងកាន់តែស៊ីជម្រៅទៅលើវប្បធម៌ខ្មែរ និងជប៉ុន តាមរយៈការចូលរួមកម្មវិធីនានាក្នុងមហោស្រពនេះ។

សម្រាប់ការចុះឈ្មោះយកព័ត៌មាន និងការសាកសួរព័ត៌មាន សូមទាក់ទងមកកាន់ផ្នែកវប្បធម៌ និងព័ត៌មាននៃស្ថានទូតជប៉ុនដែលមានទូរសព្ទលេខ ០២៣ ២១៧ ១៦១ (លេខភ្ជាប់បន្ត #១១២១) ឬ ផ្ញើមកអ៊ីម៉ែល info.jpn@pp.mofa.go.jp។ សម្រាប់ព័ត៌មានបន្ថែមស្តីពីមហោស្រពនេះ សូមចូលទៅកាន់ទំព័រហ្វេសប៊ុកផ្លូវការ «Japan Cambodia Kizuna & Tanabata»។